00171401

E11/41

**សមាគមអាដហុក**

**ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា**

ផ្ទះលេខ៣ ផ្លូវ១៥៨ ឬខកញ៉ាទ្រឿងកាង សង្កាត់បឹងរាំង ខណ្ឌដូនពេញ

លេខទូរស័ព្ទ: (៨៥៥-២៣) ២១៨៦៥៣ និង ៩៩០៥៤៤ លេខទូរសារ: (៨៥៥-២៣) ២១៧២២៩ លេខប្រអប់សំបុត្រ: ១០២៤ លេខប្រអប់សំបុត្រ លេខ២០ នៅ CCC

អ៊ីម៉ែល: adhoc@forum.org.kh វែបសាយ: www.adhoc-chra.org

---

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ.០១)

**អង្គបុរេជំនុំជម្រះ**

ចំពោះមុខ: លោកចៅក្រម ប្រាក់ គឹមសាន ជាប្រធាន

លោកចៅក្រម Rowan DOWNING

លោកចៅក្រម ន័យ ថុល

លោកស្រីចៅក្រម Katinka LAHUIS

លោកចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ២២ កុម្ភៈ ២០០៨

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
14 / 03 / 2008
ម៉ោង (Time/Heure): 15h30 PM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

---

**សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន**

ដាក់ជូនដោយ

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា

(អាដហុក)

---

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
14 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

<u>**សហព្រះរាជអាជ្ញា**</u>

លោកស្រី ជា លាង

លោក Robert PETIT

<u>**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**</u>

លោក ហុង គឹមសួន

លោក ឡោ ចាន់ធី

លោក នី ចាន់ឌី

<u>**ជនត្រូវចោទ**</u>

លោក នួន ជា

<u>**សហមេធាវី**</u>

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

**សមាគមអាដហុក**

**ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា**

ផ្ទះលេខ៣ ផ្លូវ១៥៨ ឬឧកញ៉ាទ្រឿងកាង សង្កាត់បឹងរាំង ខណ្ឌដូនពេញ

លេខទូរស័ព្ទ: (៨៥៥-២៣) ២១៨៦៥៣ និង ៩៩០៥៤៤ លេខទូរសារ: (៨៥៥-២៣) ២១៧២២៩ លេខប្រអប់សំបុត្រ: ១០២៤ លេខប្រអប់សំបុត្រ លេខ២០ នៅ CCC

អ៊ីម៉ែល: adhoc@forum.org.kh វែបសាយ: www.adhoc-chra.org

# សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដីស្ដីពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

ដាក់ជូនដោយ

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា

(អាដហុក)

**ចំពោះអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

## មុខកថា

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) ដែលត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាំងពីខែធ្នូ ឆ្នាំ១៩៩១ ហើយដែលបច្ចុប្បន្ននេះមានវត្តមាននៅគ្រប់ទិសទីក្នុងប្រទេស ធ្វើការការពារសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ ចាប់តាំងពីខែធ្នូ ឆ្នាំ១៩៩៦ ក្នុងក្របខណ្ឌនៃកម្មវិធីរបស់ខ្លួនទាក់ទងនឹងការកាត់ទោសអតីតៈមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ សមាគមអាដហុកបានដឹកនាំសកម្មភាពបង្កើនការយល់ដឹង និងផ្ដល់ព័ត៌មានជូនប្រជាជន ផ្ដល់ជំនួយផ្នែកចិត្តសាស្ត្រ យោបល់ផ្នែកច្បាប់ ការឃ្លាំមើលអង្គជំនុំជម្រះ និងវគ្គបណ្ដុះបណ្ដាលអ្នកសារព័ត៌មាន។ ជាចម្លើយទៅនឹងការអំពាវនាវរបស់អង្គបុរេជំនុំជម្រះកាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ ក្នុងឋានៈរបស់ខ្លួនជាអ្នកដែលមិនមែនជាភាគីនៃរឿងក្ដី សមាគមអាដហុកមានកិត្តិយសសូមដាក់ជូនអង្គបុរេជំនុំជម្រះនូវសារណាមួយស្ដីពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។

E11/41

## សេចក្តីផ្តើម

អង្គបុរេជំនុំជម្រះបានបើកសវនាការកាលពីថ្ងៃទី៧ និងទី៨ ខែកុម្ភៈ ឆ្នាំ២០០៨ លើរឿងក្តីនៃបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងនៅចំពោះមុខខ្លួនដោយសហមេធាវីរបស់ជនត្រូវចោទ នួន ជា ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតដែលសម្រេចដាក់លោក នួន ជា ឲ្យនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន។

ក្នុងពេលសវនាការនោះ ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួនរូប និងមេធាវីរបស់ពួកគេបានចូលរួមនៅក្នុងការពិភាក្សាដេញដោល។ ក្នុងអំឡុងពេលសវនាការនោះ សហមេធាវីរបស់លោក នួន ជា បានបដិសេធយ៉ាងច្បាស់លាស់នូវការចូលរួមនេះ ដោយលើកនូវសំអាងដូចខាងក្រោម:

- ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់ជូននូវសារណាជាលាយលក្ខណ៍អក្សរ;
- ដើមបណ្តឹងរដ្ឋប្បវេណីមិនបានជំរាបជូនទៅភាគីផ្សេងៗទៀត និងអង្គបុរេជំនុំជម្រះពីផលប្រយោជន៍របស់ខ្លួនក្នុងការប្តឹង;
- វិធាន ២៣ នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក. មិនបានចែងពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទេ។

សហមេធាវីរបស់លោក នួន ជា បានយោងតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិយកមកធ្វើជាទឡ្ហីករណ៍របស់ខ្លួន ពោលឲ្យចំគឺ តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ ក្នុងរឿងក្តីព្រះរាជអាជ្ញា តទល់នឹង Thomas Lubanga Dyilo។

សំនួរដែលយើងសាកល្បងនឹងឆ្លើយ គឺមានសេចក្តីដូចតទៅនេះ:

« តើដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នឬទេ? »



Original FR : 00164683-00164690

ចម្លើយដែលអង្គបុរេជំនុំជម្រះនឹងផ្តល់ឲ្យនឹងក្លាយទៅជាយុត្តិសាស្ត្រមួយ។ ហេតុដូចនេះ នីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះនឹងត្រូវបានពន្យល់ដោយច្បាស់លាស់លើបញ្ហាដ៏ម៉ឺងម៉ាត់នេះ ដល់ជនរងគ្រោះដែលបានប្ដឹងក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។

សេចក្តីអធិប្បាយដែលមានជាបន្តនេះ នឹងបង្ហាញពីមូលហេតុដែលនាំឲ្យយើងខ្ញុំគិតថា:

- ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននៅចំពោះមុខអង្គបុរេជំនុំជម្រះ (១),
- នៅពេលណាដែលបណ្តឹងរដ្ឋប្បវេណីត្រូវបានប្រកាសថាទទួលយកបានដោយសហចៅក្រមស៊ើបអង្កេត នោះសំនួរទាក់ទងនឹងផលប្រយោជន៍ក្នុងការប្តឹងរបស់ពួកគេមិនគួរលើកយកមកនិយាយទៀតទេ (២),
- ជាទីបញ្ចប់ ការចូលរួមរបស់ពួកគេនៅក្នុងដំណាក់កាលណាមួយក៏ដោយនៃនីតិវិធីមិនរំលោភលើសិទ្ធិរបស់ភាគីចុងចោទក្នុងការទទួលបាននូវការជម្រះក្តីប្រកបដោយយុត្តិធម៌នោះទេ (៣)។

**១. សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននៅចំពោះមុខអង្គបុរេជំនុំជម្រះ**

១.១. កថាខណ្ឌទី ១ នៃ មាត្រា ២៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សំរាប់ធ្វើការចោទប្រកាន់ទោសលើឧក្រិដ្ឋកម្មដែលកើតមានឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានប្រកាសឲ្យប្រើកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) ហៅថា ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចែងថា:

« រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្ត *តាមនីតិវិធីដែលនៅជាធរមាន*។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ » (អក្សរទ្រេតត្រូវបានគេបន្ថែម)

១.២. មាត្រា ២០ (ថ្មី) នៃច្បាប់ដដែលនេះ ចែងក្នុងន័យតែមួយក្នុងកថាខណ្ឌទី ១ របស់ខ្លួនថា:

« សហព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ដោយអនុវត្ត *តាមនីតិវិធីដែលនៅជាធរមាន*។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហព្រះរាជអាជ្ញាអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ » (អក្សរទ្រេតត្រូវបានគេបន្ថែម)

១.៣. មាត្រា៣៣ (ថ្មី) នៃច្បាប់ដដែលនេះ ចែងក្នុងន័យតែមួយក្នុងកថាខណ្ឌទី ១ របស់ខ្លួនទៀតថា:

« អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័ស *ទៅតាមនីតិវិធីជាធរមាន* ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ » (អក្សរទ្រេតត្រូវបានគេបន្ថែម)

១.៤. ជាទីបញ្ចប់ មាត្រា៣៧ (ថ្មី) នៃច្បាប់ដដែលនេះ ចែងដូចតទៅនេះ:

« ប្រការដែលបានចែងនៅក្នុងមាត្រា *៣៣* ៣៤ និង៣៥ ត្រូវអនុវត្តដូចគ្នាចំពោះការជំនុំជម្រះក្តីនៅក្នុងអង្គបុរេជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល។ » (អក្សរទ្រេតត្រូវបានគេបន្ថែម)

១.៥. កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការធ្វើការចោទប្រកាន់ទោសក្រោមច្បាប់កម្ពុជាលើឧក្រិដ្ឋកម្មដែលកើតមានឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃ ទី៦ ខែមិថុនា ឆ្នាំ២០០៣ ចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២ របស់ខ្លួនថា:

« *នីតិវិធីត្រូវតែធ្វើឡើងស្របតាមច្បាប់កម្ពុជា*។ ប្រសិនបើច្បាប់របស់កម្ពុជាពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ

ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ » (អក្សរទ្រេតត្រូវបានគេបន្ថែម)

១.៦. វាក្យខណ្ឌទី៥ និងចុងក្រោយនៃបុព្វកថារបស់វិធានផ្ទៃក្នុងរបស់អ.វ.ត.ក. ចែងថា:

« អាស្រ័យហេតុនេះ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាបានអនុម័តវិធានផ្ទៃក្នុងដូចខាងក្រោម ដែលមានគោលបំណងធ្វើការចងក្រងនូវវិធានជាធរមានរបស់កម្ពុជា សម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ និង *ដោយអនុលោមតាមមាត្រា ២០ថ្មី ២៣ថ្មី និងមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងមាត្រា ១២-១ នៃកិច្ចព្រមព្រៀង* អនុម័តវិធានមួយចំនួនបន្ថែមទៀតនៅពេលណាដែលច្បាប់កម្ពុជាជាធរមានពុំអាចដោះស្រាយបានចំពោះករណីពិសេសណាមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬ ការអនុវត្ត ឬក៏ប្រសិនបើមានបញ្ហាពាក់ព័ន្ធទាក់ទងនឹងភាពសមស្របរវាងបទប្បញ្ញត្តិនៅក្នុងច្បាប់កម្ពុជាទៅនឹងនិយាមអន្តរជាតិ។ » (អក្សរទ្រេតត្រូវបានគេបន្ថែម)

១.៧. គេអាចទាញហេតុផលពីសេចក្តីដែលមានចែងខាងលើបានថា អង្គបុរេជំនុំជម្រះនៃអ.វ.ត.ក. ដែលនីតិវិធីនៅចំពោះមុខខ្លួនជាផ្នែកមួយនៃនីតិវិធីទាំងមូលរបស់អ.វ.ត.ក. ត្រូវអនុវត្តជាបឋមនូវនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលនៅជាធរមាន។

១.៨. ផ្ទុយមកវិញ ប្រសិនបើច្បាប់របស់កម្ពុជាពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ហើយដែលត្រូវបានគេរំលឹកជាពិសេសនៅក្នុងវិធានផ្ទៃក្នុងរបស់អ.វ.ត.ក.។

១.៩. ត្រង់ចំណុចនេះ យើងសូមរំលឹកថាមានអត្ថបទច្បាប់ពីរដែលបច្ចុប្បន្ននេះជាច្បាប់ស្តីអំពីនីតិវិធីព្រហ្មទណ្ឌអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាថ្មី និងវិធានផ្ទៃ

ក្នុងរបស់អ.វ.ត.ក. ដែលវិធានផ្ទៃក្នុងនេះសាកល្បងធ្វើការសំយោគក្រមនីតិវិធីព្រហ្មទណ្ឌ ដោយធ្វើការតំរូវនីតិវិធីព្រហ្មទណ្ឌនេះទៅនឹងលក្ខណៈពិសេសនៃអង្គជំនុំជម្រះវិសាមញ្ញ។

១.១០. ទាក់ទងនឹងសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី វិធាន ២៣ នៃវិធានផ្ទៃក្នុងទាក់ទិននឹងបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដោយជនរងគ្រោះ ឬហៅម្យ៉ាងទៀតថាទាក់ទងនឹងសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី មិនបានចែងពីករណីជាក់លាក់នៃសិទ្ធិរបស់គាត់ក្នុងការចូលរួមក្នុងនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ននៅចំពោះមុខអង្គបុរេជំនុំជម្រះនោះទេ ដោយគ្រាន់តែចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌទី ៦ របស់ខ្លួនថា:

« ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមានអានុភាពដូចខាងក្រោម:

ក- ជនរងគ្រោះក្លាយជា*ភាគីក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ*។ ដើមបណ្ដឹងរដ្ឋប្បវេណី (...) អនុលោមទៅតាមវិធាន ៦២ ស្ដីពីដីកាចាត់ឲ្យស៊ើបសួរជំនួស (...) អាចត្រូវបានសាកសួរ *ក្នុងល័ក្ខខ័ណ្ឌដូចគ្នា* ជាមួយនឹងជនត្រូវចោទ ឬ ជនជាប់ចោទ។ » (អក្សរទ្រេតត្រូវបានគេបន្ថែម)

១.១១. ជាងនេះទៅទៀត កថាខណ្ឌទី ៧ នៃវិធានដដែលនេះឲ្យនិយមន័យដើមបណ្ដឹងរដ្ឋប្បវេណីថាជាជនរងគ្រោះ « *ដែលចូលរួមក្នុងនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ* »។ ម្យ៉ាងទៀត វាក្យខណ្ឌ ង នៃកថាខណ្ឌនេះ ចែងពីបទប្បញ្ញត្តិទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីរបស់ខ្លួន ដែលអាចអនុវត្តបាន « *នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអ.វ.ត.ក.* »។

១.១២. វាហាក់ដូចជាផ្ទុយពីអ្វីដែលបានចែងខាងលើ នៅពេលដែលគេហាមឃាត់ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ព្រោះថា វិធានផ្ទៃក្នុងបានចែងពីការចូលរួមនេះនៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងមូលរបស់អ.វ.ត.ក.។

១.១៣. យើងសូមរំលឹកថា នីតិវិធីព្រហ្មទណ្ឌដែលនៅជាធរមាននៅក្នុងប្រទេសកម្ពុជាគឺជានីតិវិធីមួយតាមលំនាំប្រទេសបារាំង។ ដើម្បីធ្វើឲ្យជឿលើរឿងនេះបាន យើងគ្រាន់តែអានក្រមនីតិវិធីព្រហ្មទណ្ឌបារាំង និងកម្ពុជាទាំងអស់ ហើយយកមកធ្វើការប្រៀបធៀបគ្នា។ ប៉ុន្តែ នៅក្នុងនីតិវិធីព្រហ្មទណ្ឌបារាំង គេយល់ថា ការស៊ើបសួរជាផ្នែកមួយនៃនីតិវិធីទាំងមូលរបស់តុលាការព្រហ្មទណ្ឌ។

វាមិនមែនដាច់ចេញពីនីតិវិធីនោះទេ។ គោលការណ៍នៃការបែងចែករវាងអំណាចការចោទប្រកាន់ និងអំណាចសាលក្រម មិនមែនមានន័យថាជានីតិវិធីដែលចែកជាផ្នែកៗនោះទេ។ ដំណាក់កាលទាំងពីរនៃការស៊ើបសួរ និងសាលក្រម រួមគ្នាបង្កើតបានជារបៀបទូទៅនៃនីតិវិធីព្រហ្មទណ្ឌ ដែលក្នុងអំឡុងពេលនៃនីតិវិធីនោះភាគីទាំងអស់មានវត្តមាន ដោយឥតរើសអើង និងដោយស្មើភាពគ្នា។

១.១៤. ហេតុដូច្នេះ យើងសូមអនុញ្ញាតជំរាបលោកឲ្យប្រុងប្រយ័ត្នចំពោះរាល់ការធ្វើឲ្យខូចទំរង់សារជាតិវន្តនៃនីតិព្រហ្មទណ្ឌជាទំរង់ដែលនៅជាធរមាននៅកម្ពុជា និងស្របច្បាប់ នៅចំពោះមុខ អ.វ.ត.ក.។ ដោយផ្អែកលើដំណាក់កាលផ្សេងៗនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា នៅពេលដែលលោកអនុវត្តនៅក្នុងអង្គបុរេជំនុំជម្រះរបស់លោក (ដែលយើងសូមទទូចលើចំណុចនេះ) ដោយជាភាគៗ ឬដោយមិនយកចិត្តទុកដាក់រក្សានូវតុល្យភាពនៅក្នុងរបៀបទូទៅនៃនីតិវិធីនេះ ជាការប្រថុយបង្កើតនីតិវិធីព្រហ្មទណ្ឌថ្មីមួយទៀតដែលមិនច្បាស់លាស់ និងមិនបានលទ្ធផលល្អ ឬផ្ទុយនឹងបទដ្ឋានអន្តរជាតិថែមទៀតផង។

១.១៥. ក្នុងករណីដែលលោកនៅតែមានភាពមន្ទិលសង្ស័យ វានឹងមិនមែនជាការឥតប្រយោជន៍នោះទេ ប្រសិនបើអង្គបុរេជំនុំជម្រះរបស់លោកធ្វើការស្នើសុំយោបល់ពីអ្នកជំនាញម្នាក់ ដែលមានចំណេះដឹងគ្រប់គ្រាន់លើនីតិព្រហ្មទណ្ឌបារាំង។ អ្នកជំនាញនេះអាចជួយលោក ជាពិសេសក្នុងការបំភ្លឺពីផលប៉ះពាល់លើនីតិវិធីដែលនៅសល់នៅចំពោះមុខអង្គបុរេរបស់លោក និងមុខអង្គជំនុំជម្រះផ្សេងទៀតរបស់ អ.វ.ត.ក. ដោយការបដិសេធរបស់លោកមិនផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីនូវសិទ្ធិចូលរួមក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

១.១៦. ស្របតាមវិធានដែលគេហៅថា *lex specialis* ជាគោលការណ៍ទូទៅនៃច្បាប់ នៅចំពោះមុខអត្ថបទពីរ អត្ថបទដែលជាក់លាក់ជាងគេត្រូវគេយកទៅអនុវត្ត។ ដោយយល់ដល់ភាពគ្មានបញ្ញត្តិរបស់វិធានផ្ទៃក្នុងរបស់អ.វ.ត.ក.លើបញ្ហាទាក់ទងនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ហេតុនេះលោកត្រូវតែមើលថាតើបញ្ហានេះត្រូវបានគេដោះស្រាយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីឬទេ។

១.១៧. ក្នុងន័យនេះ វិធាន ២ នៃវិធានផ្ទៃក្នុងដដែលនេះ ទាក់ទងនឹងនីតិវិធីអនុវត្តនៅចំពោះមុខ អ.វ.ត.ក.សម្រាប់បញ្ហាចន្លោះប្រហោងនៅក្នុងវិធានផ្ទៃក្នុង ចែងយ៉ាងច្បាស់លាស់ថា:

« នៅក្នុងអំឡុងពេលដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើមានបញ្ហាណាមួយកើតមានឡើងដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវធ្វើការសម្រេចចិត្ត ដោយស្របទៅលើមាត្រា ១២-១ នៃកិច្ចព្រមព្រៀង និងមាត្រា ២០ថ្មី ២៣ថ្មី ៣៣ថ្មី ឬមាត្រា៣៧ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនេះ ហើយនិង *ច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន* (...)។ » (អក្សរទ្រេតត្រូវបានគេបន្ថែម)

១.១៨. ហេតុដូចនេះ យើងសូមទាញការយកចិត្តទុកដាក់របស់លោកលើមាត្រា ២៥៨ និងមាត្រា ២៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ដែលគេបញ្ចូលទៅក្នុងមាតិកាទី ២ ទាក់ទងនឹងសភាស៊ើបសួរ ហើយដែលមានចែងដូចតទៅនេះ:

« **មាត្រា ២៥៨ (ការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ)**

ប្រធានសភាស៊ើបសួរពិនិត្យផ្ទៀងផ្ទាត់មើលថា តើសំណុំរឿងមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបានឬទេ រួចហើយកំណត់កាលបរិច្ឆេទបើកសវនាការ។ ប្រធានសភាស៊ើបសួរជូនដំណឹងដោយផ្ទាល់មាត់អំពីកាលបរិច្ឆេទនៃការបើកសវនាការ ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការនេះ ដល់គូភាគី និងដល់មេធាវី។

ការជូនដំណឹងដល់ជនត្រូវចោទដែលត្រូវបានឃុំខ្លួន ត្រូវធ្វើដូចតទៅនេះ:

- ដោយផ្ទាល់មាត់ ឬ
- តាមរយៈប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។

ការជូនដំណឹងដល់ជនត្រូវចោទនៅក្រៅឃុំ *ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងដល់មេធាវី* ត្រូវធ្វើដូចតទៅ:

- ដោយផ្ទាល់មាត់
- តាមផ្លូវរដ្ឋបាល ឬ
- តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។

កាលណាការជូនដំណឹងធ្វើដោយផ្ទាល់មាត់ ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការជូនដំណឹង នៅរឹមទំព័រនៃដីកា។ ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីចុះហត្ថលេខា របស់ខ្លួន។

ក្នុងករណីផ្សេងទៀត ការជូនដំណឹងត្រូវធ្វើដោយការប្រគល់សេចក្តីចម្លងដីកា ដោយមានចំណារទទួល។

**មាត្រា ២៥៩ (ការពិគ្រោះសំណុំរឿង និងសារណា)**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវី អាចពិនិត្យមើលសំណុំរឿងរហូតដល់ពេលបើកសវនាការ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវប្រគល់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដល់ក្រឡាបញ្ជីយ៉ាងយូរបំផុតមួយថ្ងៃមុនពេលសវនាការ។

គូភាគី និងមេធាវី*អាច*ប្រគល់សារណាដល់ក្រឡាបញ្ជី (...) » (អក្សរទ្រេតត្រូវបានគេបន្ថែម)។

១.១៩.ម្យ៉ាងទៀត មាត្រា ២៦៧ នៃក្រមដដែលនេះចែងថា:

« **មាត្រា ២៦៧ (បណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរដោយជនត្រូវចោទ)**

ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ចំពោះដីកាដូចតទៅ:

(...)

- *ដីកាស្តីពីរឿងឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការដូចដែល មានចែងក្នុងផ្នែកទី ៥ (ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន)* និងផ្នែកទី ៧ (ស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃជំពូកទី ៣ ស្តីពីវិធានការនិវន្តភាយ ក្នុងមាតិកាទី ១ នៃគន្ថីនេះ និងមាត្រា ២៤៩ (សេចក្តីសម្រេចនៃដីកាដំណោះស្រាយទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ » (អក្សរទ្រេតត្រូវបានគេបន្ថែម)។ ផ្នែកទី ៥ (ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន) ដែលគេយកជាសេចក្តីយោងនេះមានចាប់ពីមាត្រា ២០៣ ដល់មាត្រា ២១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១.២០. លោកគួរតែយកគំនិតតាមច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលនៅជាធរមាន ហើយមើលថា តើលើបញ្ហាដែលចោទចំពោះលោកនេះ អង្គបុរេជំនុំជម្រះបំពេញនាទីជាសភាស៊ើបសួរនៃសាលាឧទ្ធរណ៍កម្ពុជានៃនីតិវិធីរួមឬទេ។

00171411

C11/41

១.២១. លើសពីនេះទៅទៀត និម្មាបនកម្មរបស់អ.វ.ត.ក. មិនស្របគ្នាជាមួយនិម្មាបនកម្មរបស់យុត្តាធិការព្រហ្មទណ្ឌអន្តរជាតិណាមួយនោះទេ។ ជាឧទាហរណ៍ ស្ថាប័នចៅក្រមស៊ើបអង្កេត និងស្ថាប័នដើមបណ្ដឹងរដ្ឋប្បវេណី មិនមានទាំងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ទាំងនៅតុលាការអន្តរជាតិ *Ad hoc* ផ្សេងទៀត។ អង្គបុរេជំនុំជម្រះរបស់លោកនឹងមិនអាចរកឃើញនូវសេចក្តីយោងជាក់លាក់ណាមួយនៅក្នុងយុត្តិសាស្ត្ររបស់យុត្តាធិការទាំងនេះ ដើម្បីដោះស្រាយបញ្ហានៃការចូលរួមរបស់ដើម បណ្ដឹងរដ្ឋប្បវេណីនៅក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ។

១.២២. ផ្អែកលើវិចារណកិច្ចនេះដ៏ទំនងនេះ លោកអាចសំអាងសេចក្តីសម្រេចរបស់លោកក្នុងការផ្តល់ដល់ដើមបណ្ដឹងរដ្ឋប្បវេណីនូវសិទ្ធិចូលរួមក្នុងនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ននៅចំពោះមុខអង្គបុរេរបស់លោក ដោយយោងទៅលើមាត្រា ២៥៨ និង មាត្រា ២៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ដោយតំរូវធ្វើយ៉ាងណាឲ្យមាត្រាទាំងនេះអាចអនុវត្តបាននៅចំពោះមុខអង្គបុរេជំនុំជម្រះរបស់លោក។

១.២៣. ស្របតាមយុត្តិសាស្ត្រដ៏ជាក់លាក់មួយនៅក្នុងនីតិអន្តរជាតិ លោកមានអំណាចចាត់ចែងសមត្ថកិច្ចរបស់លោកដោយផ្ទាល់បាន។ អំណាចនេះ ដែលជាអំណាចពិសេសរបស់គ្រប់យុត្តាធិការអន្តរជាតិ នឹងអនុញ្ញាតឲ្យលោកដោះស្រាយបញ្ហានេះជាស្ថាពរសំរាប់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នដែលនឹងអាចមាននៅថ្ងៃអនាគត នៅចំពោះមុខអង្គបុរេជំនុំជម្រះរបស់លោក។

១.២៤.ម្យ៉ាងវិញទៀត អង្គបុរេជំនុំជម្រះរបស់លោកមានផលប្រយោជន៍ទាំងស្រុងក្នុងការបញ្ឈប់ជាស្ថាពរនូវការយោងទៅដល់យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ ដូចដែលត្រូវបានរំលើកពីមុនរួចហើយ (នៅចំណុច ១.២១.) របៀបចាត់ចែងរបស់អ.វ.ត.ក. គឺខុសគ្នាជាសារវន្ត ពីរបៀបចាត់ចែងរបស់យុត្តាធិការព្រហ្មទណ្ឌអន្តរជាតិ *Ad hoc* ផ្សេងៗទៀត រួមទាំងចំណាត់ការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផងដែរ។ ដូចបានបង្ហាញពីមុនរួចហើយ នីតិវិធីរបស់អ.វ.ត.ក. គឺជានីតិវិធីបែបបារាំង ដែលជាផ្នែកមួយនៃគ្រួសារគតិយុត្តរ៉ូម៉ាណូ-ហ្សែរម៉ានិក។ ចំណែកយុត្តាធិការ

ព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀតវិញ គេសុទ្ធតែប្រើប្រាស់នីតិវិធីដែលជាប្រភេទ អង់គ្លេ-សាក់ស៊ុង (Common Law) ទាំងអស់។

១.២៥. ស្ថាប័នគតិយុត្តនៃដើមបណ្តឹងរដ្ឋប្បវេណី គឺជាឧទាហរណ៍ជាក់ច្បាស់មួយ។ ស្ថាប័នគតិយុត្ត នេះគឺមិនត្រូវបានគេស្គាល់ទាំងស្រុងនៅក្នុងប្រព័ន្ធអង់គ្លេ-សាក់ស៊ុងទេ។ គ្មានយុត្តាធិការព្រហ្មទណ្ឌ អន្តរជាតិ *Ad hoc* ពីមុនៗណាមួយស្គាល់ស្ថាប័ននេះឲ្យចំនោះទេ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ ទោះបីជាអនុញ្ញាតការចូលរួមរបស់ជនរងគ្រោះ ក៏មិនទទួលស្គាល់ចំពោះពួកគាត់ក្នុងឋានៈជា *ភាគី នៃរឿងក្តី* នោះដែរ (យើងសូមគូសបញ្ជាក់លើពាក្យថា « *ភាគីនៃរឿងក្តី* »)។ ហេតុដូចនេះ ទោះជាក្នុងករណីណាក៏ដោយ សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ ក្នុងរឿងក្តី *ព្រះរាជអាជ្ញា តទល់នឹង Thomas Lubanga Dyilo* មិនអាចយកទៅប្រើប្រាស់ជា សេចក្តីយោងជាយុត្តិសាស្ត្រសំរាប់បញ្ហាដែលចោទឡើងនៅទីនេះ នៅចំពោះមុខអង្គបុរេជំនុំជម្រះរបស់ លោកនោះទេ។ ភាគីចុងចោទលើកបញ្ហានេះឡើង គឺខុសហើយ។

១.២៦. ដោយហេតុនេះ នាពេលអនាគត លោកត្រូវបំបាត់ជាស្ថាពរនូវរាល់ការភ័ន្តច្រឡំដែលនឹង មានលើបញ្ហានេះ ដោយប្រកាសថាយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមិនសមស្រប ក្នុងការដោះស្រាយបញ្ហាប្រឈមមុខចំពោះមុខលោក ទាក់ទងនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

**២. ផលប្រយោជន៍ក្នុងការប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

២.១. វិធាន ២៣ នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក.ចែងថា:

> « **វិធាន ២៣០: បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយជនរងគ្រោះ**
>
> ១. *គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី* នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី:
>
> ក- *ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះ ឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់* និង
>
> ខ- អនុញ្ញាតឲ្យជនរងគ្រោះអាចស្វែងរកសំណងផ្លូវចិត្ត និងសម្ភារភាព ដូចមានចែង ក្នុងវិធាននេះ។

២. សិទ្ធិធ្វើបណ្តឹងរដ្ឋប្បវេណីអាចធ្វើឡើងដោយជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ ដោយគ្មានការរើសអើងចំពោះលក្ខណៈវិនិច្ឆ័យ ដូចជាលំនៅដ្ឋានបច្ចុប្បន្ន ឬសញ្ជាតិឡើយ។ ដើម្បីឲ្យពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន ព្យសនកម្មត្រូវតែជាៈ

ក- ការខូចខាតរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និង

ខ- ជាផលវិបាកដោយផ្ទាល់ពីបទល្មើស ជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដមកទល់ពេលបច្ចុប្បន្ន។

៣. នៅពេលណាក៏ដោយក្នុងអំឡុងពេលស៊ើបសួរ ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សររបស់ខ្លួនទៅសហចៅក្រមស៊ើបអង្កេត ដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ អនុលោមទៅតាមបទប្បញ្ញត្តិស្តីពីការការពារជនរងគ្រោះដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងនេះទៅសហព្រះរាជអាជ្ញា និងជនត្រូវចោទ។ សហចៅក្រមស៊ើប អង្កេតអាចសម្រេចចេញដីកាដោយមានសំអាងហេតុបដិសេធពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណីបាន។ ដីកានេះត្រូវបើកផ្លូវប្តឹងឧទ្ធរណ៍ដល់ជនរងគ្រោះ។

៤. ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅអង្គជំនុំជម្រះសាលាដំបូងរហូតដល់ពេលបើកសវនាការ។ ពាក្យបណ្តឹងនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ប្រគល់ឲ្យក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង និងត្រូវដាក់បញ្ចូលទៅក្នុងកំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី។ *ជនរងគ្រោះដែលបានដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលស៊ើបសួរ មិនតម្រូវឲ្យដាក់ពាក្យជាថ្មីម្តងទៀតនៅចំពោះមុខអង្គជំនុំជម្រះឡើយ។* » (អក្សរទ្រេតត្រូវបានគេបន្ថែម)

២.២. បញ្ហាផលប្រយោជន៍ក្នុងការប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនគួរមានទៀតទេទោះជានៅដំណាក់កាលណាមួយក៏ដោយនៃនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ នៅពេលដែលបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយជនរងគ្រោះត្រូវបានប្រកាសថាអាចទទួលបាន ដោយសហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមកថាខណ្ឌទី ៤ នៃវិធាន ២៣ ខាងលើ ដែលចែងយ៉ាងច្បាស់លាស់ថា « *ជនរងគ្រោះដែលបានដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលស៊ើបសួរ មិនតម្រូវឲ្យដាក់ពាក្យជាថ្មីម្តងទៀតនៅចំពោះមុខអង្គជំនុំជម្រះឡើយ* »។

២.៣. ជាងនេះទៅទៀត យោងតាមកថាខណ្ឌទី ១ វាក្យខណ្ឌ ក នៃវិធាន ២៣ ខាងលើ ផលប្រយោជន៍ជាពិសេសក្នុងការប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺ « *ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់* »។ ប៉ុន្តែ បណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ថ្លែងយ៉ាងជាក់លាក់អំពីបញ្ហាដែលទាក់ទងជាសារវន្តដល់ការបង្កើតទំនួលខុសត្រូវរបស់ចារីនៃឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ ចំពោះសម្ពាធដែលធ្វើឡើងចំពោះសាក្សី ឬជនរងគ្រោះ ការព្រមព្រៀងគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតម្នាក់ ឬច្រើន ការរក្សាទុកនូវភស្តុតាងជាសម្ភារៈ ការធានាថាជនត្រូវចោទស្ថិតក្នុងឱវាទរបស់តុលាការ ការការពារជនត្រូវចោទ និងការរំខានដល់សណ្តាប់ធ្នាប់សាធារណៈដែលមានអានុភាពអាចបំផ្លាញរឿងក្តីនោះបាន សុទ្ធតែជាបញ្ហាដែលទាក់ទងនឹងការសម្រេចបានផលល្អ ឬការមិនបានសម្រេចនៃការចោទប្រកាន់លើជនដែលទទួលខុសត្រូវខាងព្រហ្មទណ្ឌនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ហើយដែលមានការទាក់ទងជាពិសេសដោយតាមផ្លូវច្បាប់ចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

២.៤. ដោយជាការបន្ថែមមួយដែលឥតប្រយោជន៍ យើងខ្ញុំសូមចង្អុលផងដែរដើម្បីជាការប្រុងប្រយ័ត្នថា យុត្តិសាស្ត្របារាំងរបស់សាលាវិនិច្ឆ័យទទួលស្គាល់បណ្តឹងរដ្ឋប្បវេណី ចំពោះបទល្មើសបង្កើតឧបសគ្គដល់ការធ្វើឲ្យលេចឡើងនូវការពិត (សាលាឧក្រិដ្ឋ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០, ព្រឹត្តិប័ត្រលេខ៧៨)។

២.៥. ជាចុងក្រោយ យើងសូមសួរមួយសំនួរថា « តើត្រូវឲ្យតម្លៃណាមួយដល់ការពោលអះអាងរបស់ភាគីចុងចោទនៅពេលដែលគាត់ថ្លែងថាវានឹងគ្មានប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ក្នុងករណីដោះលែងជនជាប់ឃុំឲ្យនៅក្រៅឃុំ ចំពោះសេចក្តីថ្លែងក្នុងន័យផ្ទុយរបស់ជនរងគ្រោះដែលសំដែងឡើងជាពិសេសក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលយើងដឹងថាការជំនុំជម្រះប្រព្រឹត្តទៅនៅក្នុងប្រទេសមួយដែលពោរពេញទៅដោយជនរងគ្រោះយ៉ាងច្រើន? »។

**៣. ការគោរពសិទ្ធិរបស់ភាគីចុងចោទក្នុងការទទួលបាននូវការជម្រះក្តីដោយយុត្តិធម៌**

៣.១. ដើម្បីដឹងថាតើវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទ និងដែលត្រូវបានគេឃុំខ្លួនបណ្តោះអាសន្ន ក្នុងការទទួលបាននូវការជម្រះក្តីដោយយុត្តិធម៌មួយ ដូចដែលគេព្រមព្រៀងហើយនៅក្នុងនីតិអន្តរជាតិឬទេ លោកត្រូវសើរើមើលយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបនៃសិទ្ធិមនុស្ស។ នៅក្នុងយុត្តាធិការអន្តរជាតិនេះ បញ្ហាជាច្រើន ដូចជាបញ្ហាដែលចោទឡើងនៅចំពោះមុខលោកជាដើម ត្រូវបានគេលើកឡើងបន្ទាប់ពីការជួបប្រទះគ្នារវាងប្រព័ន្ធគតិយុត្តអឺរ៉ុបទាំងពីរ គឺប្រព័ន្ធអង់ហ្គ្លោ-សាក់សុង និងប្រព័ន្ធរ៉ូម៉ាណូ-ហ្សែកម៉ានិក។

៣.២. ម្យ៉ាងវិញទៀត តុលាការនៃ Strasbourg បានលាតសន្ធឹងយុត្តិសាស្ត្ររបស់ខ្លួនក្នុងរឿងព្រហ្មទណ្ឌ ទាក់ទងនឹងសិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌។ សំនួរដែលចង់ដឹងថាតើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីប៉ះពាល់ឬទេដល់សិទ្ធិរបស់ភាគីចុងចោទក្នុងការទទួលបានការជម្រះក្តី ដោយយុត្តិធម៌ ដូចដែលបានព្រមព្រៀងក្នុងមាត្រា៦ កថាខណ្ឌទី ១ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាព ត្រូវបានសិក្សាដោយតុលាការអឺរ៉ុបនៃសិទ្ធិមនុស្ស។ វាហាក់ដូចជាសេចក្តីសម្រេចរបស់តុលាការនេះយល់ស្របតាមចម្លើយមួយជាអវិជ្ជមាន។ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនប៉ះពាល់ទេដល់សិទ្ធិរបស់ភាគីចុងចោទក្នុងការទទួលបានការជម្រះក្តីមួយដោយយុត្តិធម៌។